  

# បទបង្ហាញ
# ស្តីពី
# បទពិសោធន៍ក្នុងការអនុវត្តការងារផ្តល់សេវាសង្គម
# និងអនាម័យបរិស្ថាន

ខេត្ត សៀមរាប

ស្រុក ស្រីស្នំ

រដ្ឋបាលឃុំមោង

បង្ហាញដោយៈ លោក ទិន ទី មេឃុំមោង

# មាតិកា


I. សេចក្ដីផ្ដើម

១.ស្ថានភាពភូមិសាស្ត្រ

២.សក្ដានុពល និងចំណុចពិសេស

II. ការគ្រប់គ្រង ការប្រើប្រាស់ថវិការបស់ឃុំ ចាប់ពីឆ្នាំ២០២២-២០២៥

III. សមិទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ព្រមជាមួយការគាំពារសង្គម

IV. បទពិសោធន៍ល្អៗ បញ្ហាប្រឈម និងសំណូមពរ

## I.សេចក្តីផ្តើម

### ១.ស្ថានភាពភូមិសាស្រ្ត




រដ្ឋបាលឃុំមោង គឺជាឃុំមួយក្នុងចំណោមឃុំទាំង៦ក្នុងស្រុកស្រីស្នំ មានផ្ទៃដីសរុប៨៦.២១គីឡូម៉ែត្រការ៉េ មាន៥ភូមិ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦៨ ចម្ងាយ១០គីឡូម៉ែត្រពីសាលាស្រុកស្រីស្នំ និងមានព្រំប្រទល់៖

- ខាងជើងទល់នឹងឃុំជ្រោយនាងងួន
- ខាងត្បូងទល់នឹងឃុំសែនសុខ ស្រុកក្រឡាញ់
- ខាងលិចទល់នឹងឃុំត្រាំសសរ
- ខាងកើតទល់នឹងឃុំស្រែខ្វាវ ស្រុកអង្គរជុំ។

មានប្រជាពលរដ្ឋសរុបចំនួន៥.៨៦៥នាក់ ស្រី៣.១៣៤នាក់ ស្មើនឹង១.៣៥៨គ្រួសារ ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង៣.៩២៩នាក់ ស្រី២.១២៦នាក់។ គ្រួសារក្រីក្រដែលទទួលបានប័ណ្ណក្រីក្រមានចំនួន៣០៤គ្រួសារ (ក្រ.១ មាន១៣០គ្រួសារ និងក្រ.២ មាន១៧៤ គ្រួសារ ) គ្រួសារពិការមាន ១៤១នាក់។ ឃុំមោងមានសមាជិកក្រុមប្រឹក្សាឃុំចំនួន០៥រូប ស្រី០២រូប

# ផែនទីព្រំប្រទល់រដ្ឋបាល ឃុំមោង ស្រុកស្រីស្នំ ខេត្តសៀមរាប



# I.សេចក្តីផ្តើម (ត)

## ២.សក្តានុពល និងចំណុចពិសេស

សក្តានុពលៈ

- ឃុំមោងមានទីតាំងដែលអាចភ្ជាប់ទៅនឹងតំបន់ជិតខាងបានងាយស្រួល ដែលជួយសម្រួលដល់ការធ្វើដំណើរ ការដឹកជញ្ជូន និងការផ្លាស់ប្តូរទំនិញ
- មានផ្ទៃដីដាំដុះធំទូលាយ អំណោយផលខ្លាំងដល់ការធ្វើកសិកម្មបែបទំនើប ជាពិសេសការដាំដុះដំណាំ ស្វាយចន្ទី និង ស្រូវវស្សា និងធនធានធម្មជាតិដែលអាចប្រើប្រាស់សម្រាប់ការបង្កើតផលិតភាព។
- ប្រជាពលរដ្ឋមានបទពិសោធន៍ក្នុងការប្រកបរបរកសិកម្ម និងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន
- អាជ្ញាធរឃុំ សហការល្អជាមួយភូមិ អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ
- ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ប្រព័ន្ធទឹកស្អាត និងអគ្គិសនី ត្រូវបានកែលម្អជាបន្តបន្ទាប់
- ទទួលបានគម្រោងអភិវឌ្ឍន៍នានាដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការលើកកម្ពស់សុខភាព ការអប់រំ និងការកាត់បន្ថយភាពក្រីក្រ។

ចំណុចពិសេសៈ

- ឃុំមោងជាតំបន់ដែលមានការអភិរក្សព្រៃឈើ និងដាំកូនឈើឡើងវិញយ៉ាងសកម្មដើម្បីបង្កើនគម្របបៃតង និងស្ថិតនៅជាប់ផ្លូវជាតិលេខ៦៨ដែលអាចតភ្ជាប់ទៅផ្លូវជាតិលេខ៦ ឆ្ពោះទៅកាន់ក្រុងសៀមរាប និងតំបន់អង្គរបាន

# II.ការគ្រប់គ្រង ការប្រើប្រាស់ថវិការបស់ឃុំចាប់ពីឆ្នាំ២០២២-២០២៥

- ❑ ប្រភពថវិកានិងចំនួនថវិកាឃុំ សង្កាត់ដែលទទួលបានពីថ្នាក់ជាតិ(២០២២-២០២៥)មានៈ
  - ឆ្នាំ២០២២ សរុបរួម ៤២៥,០០០,០០០រៀលគត់
  - ឆ្នាំ២០២៣ សរុបរួម ៤៩៥,០០០,០០០រៀលគត់
  - ឆ្នាំ២០២៤ សរុបរួម ៤០១,០០០,០០០រៀលគត់ (សេវាសង្គមនិងអនាម័យបរិស្ថាន ៣៥,០០០,០០០រៀលគត់)
  - ឆ្នាំ២០២៥ សរុបរួម ៤៥៨,៦០០,០០០រៀលគត់ (សេវាសង្គមនិងអនាម័យបរិស្ថាន ៥៨,០០០,០០០រៀលគត់)
- ❑ **ការប្រើប្រាស់ថវិការបស់ឃុំ**
  - បានប្រជុំគ្រោងថវិកាតាមតម្រូវការសកម្មភាពនៃឆ្នាំនីមួយៗ និងបានអនុម័តដោយក្រុមប្រឹក្សាឃុំ
- ❑ **ការអនុវត្តថវិកា**
  - បានឧបត្ថម្ភជូនគ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន៥ថ្នាក់ និងទិញសម្ភារៈសិក្សា
  - ចុងភៅចម្អិនអាហារតាមសាលាចំនួន៣សាលា
  - គាំទ្រគម្រោងគណនេយ្យភាពសង្គម
  - គាំទ្រគម្រោងក្រុមឪពុកម្ដាយ
  - គាំទ្រគម្រោងភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព
  - គាំទ្រគម្រោងបរិស្ថានស្អាត
  - គាំទ្រកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក.

## តារាងបែងចែកថវិកាឆ្នាំ២០២៤

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1712 | ស្រីស្នំ | | | | | | | |
| 171201 | ជ្រោយនាងងួន | 7 | 7 | 260.00 | 14.00 | 37.00 | 179.00 | 490.00 |
| 171202 | ក្លាំងហាយ | 5 | 7 | 230.00 | 12.00 | 32.00 | 148.00 | 422.00 |
| 171203 | ត្រាំសសរ | 5 | 7 | 230.00 | 12.00 | 36.00 | 173.00 | 451.00 |
| 171204 | មោង | 5 | 5 | 197.00 | 10.00 | 35.00 | 159.00 | 401.00 |
| 171205 | ប្រីយ៍ | 5 | 5 | 197.00 | 10.00 | 33.00 | 150.00 | 390.00 |
| 171206 | ស្លែងស្ពាន | 5 | 8 | 246.00 | 13.00 | 42.00 | 214.00 | 515.00 |
| | សរុបរង | 32 | 39 | 1,360.00 | 71.00 | 215.00 | 1,023.00 | 2,669.00 |

## តារាងបែងចែកថវិកាឆ្នាំ២០២៥

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1712 | ស្រីស្នំ | | | | | | | |
| 171201 | ជ្រោយនាងងួន | 7 | 7 | 279.30 | 16.20 | 61.00 | 198.00 | 554.50 |
| 171202 | ក្លាំងហាយ | 5 | 7 | 247.20 | 14.30 | 55.00 | 166.00 | 482.50 |
| 171203 | ត្រាំសសរ | 5 | 7 | 247.20 | 14.30 | 58.00 | 188.00 | 507.50 |
| 171204 | មោង | 5 | 5 | 212.30 | 12.30 | 58.00 | 176.00 | 458.60 |
| 171205 | ប្រីយ៍ | 5 | 5 | 212.30 | 12.30 | 54.00 | 163.00 | 441.60 |
| 171206 | ស្លែងស្ពាន | 5 | 8 | 264.70 | 15.30 | 69.00 | 236.00 | 585.00 |
| | សរុបរង | 32 | 39 | 1,463.00 | 84.70 | 355.00 | 1,127.00 | 3,029.70 |

# II.ការគ្រប់គ្រង ការប្រើប្រាស់ថវិការបស់ឃុំចាប់ពីឆ្នាំ២០២២-២០២៥ (ត)

- ដើមអាណត្តិរបស់ក្រុមប្រឹក្សាបានរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិលជារៀងរាល់ឆ្នាំ
- ការគ្រោងថវិការៀបចំទៅតាមផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលតាមសំណើ សំណូមពរដែលប្រជាពលរដ្ឋបានស្នើឡើង
- អាណត្តិក្រុមប្រឹក្សាឃុំបានប្រជុំប្រចាំខែបានទៀងទាត់។








# III.សមិទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ព្រមជាមួយការខារគាំពារសង្គម

- **មត្តេយ្យសិក្សាសហគមន៍:**



- បច្ចុប្បន្នមត្តេយ្យសិក្សាសហគមន៍បានសាងសង់ចំនួន៥សាលា ដែលបានបណ្តុះបណ្តាលសិស្សចាប់ពីឆ្នាំ២០២២-២០២៥ សរុបចំនួន ៤០៩នាក់ ស្រី២៣០នាក់។
- សាលាមត្តេយ្យសិក្សាសហគមន៍ឃុំមោង បានទទួលស្គាល់ជាសាលាស្តង់ដាអប្បបរមាសិក្សាសហគមន៍ពីក្រសួងអប់រំ យុវជន និងកីឡាចំនួន៣សាលា ក្នុងនោះគ្រូទទួលថវិកាបន្ថែមក្នុង១ខែ៧៩០,០០០រៀល ក្នុងមួយនាក់។
- រៀបចំកែលម្អសាលារៀនឱ្យមានភាពទាក់ទាញ មានសោភណភាព និងផាសុកភាព
- គ្រូបង្រៀនមានវិជ្ជាជីវៈបានចូលរៀនវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសបង្រៀនច្បាស់លាស់







# III.សមិទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ព្រមជាមួយការគាំពារសង្គម (ត)

- **ការងារជួយជនងាយរងគ្រោះ:**
  - ឃុំមោងតែងតែយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋដែលមានជីវភាពលំបាក
  - ចុះសួរសុខទុក្ខប្រជាពលរដ្ឋទីទាល់ក្រ និងផ្តល់ជាកញ្ចប់ថវិកា និងស្បៀងអាហារ
- **ការជួយទប់ស្កាត់វិបត្តិនានា:**
  - បានចុះអន្តរាគមន៍ នៅពេលមានគ្រោះធម្មជាតិដូចជាខ្យល់កន្ត្រាក់រលំផ្ទះប្រជាពលរដ្ឋ ដោយបានជួយរៀបចំផ្ទះឡើងវិញ និងបានជួយប្រជាពលរដ្ឋនៅពេលមានជំងឺដោយបានផ្តល់ជាថវិកានិងស្បៀងអាហារ
  - ចុះត្រួតពិនិត្យលើស្ថានភាពស្រូវរបស់ប្រជាពលរដ្ឋនៅពេលមានទឹកជំនន់









## III.សមិទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ព្រមជាមួយការងារគាំពារសង្គម (ត)

- **ការងារយេនឌ័រៈ** ឃុំមោងតែងតែផ្សព្វផ្សាយអំពីយេនឌ័រ លើកកម្ពស់តួនាទីស្ត្រីនៅក្នុងសហគមន៍ និងផ្សព្វផ្សាយពីបញ្ហានៃការប្រើប្រាស់អំពើហិង្សា និងទប់ស្កាត់ការប្រើប្រាស់អំពើហិង្សា ដោយធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋជ្រាបច្បាស់និងយល់ដឹងពីផលប៉ះពាល់។
- **ការងារអនាម័យបរិស្ថានៈ**
  - តែងតែបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមសម្អាតបរិស្ថាន ផ្សព្វផ្សាយពីផលប៉ះពាល់នៃសំរាម និងការគ្រប់គ្រងសំរាម។
  - បានដឹកនាំនិងជំរុញប្រជាពលរដ្ឋឱ្យចូលរួមថែរក្សាការពារព្រៃឈើ និងដាំដើមឈើបន្ថែម











## III.សមិទ្ធផលដែលសម្រេចបានតាមរយៈការអនុវត្តគម្រោង/សកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន ព្រមជាមួយការខារគាំពារសង្គម ( ត )



❑ **គម្រោងនេះបានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដូចជា៖**

- សម្រាប់កុមារតូចៗនៅក្នុងឃុំមោងទទួលបានការអប់រំដំបូងប្រកបដោយគុណភាព មានសុវត្ថិភាព នៅជិតផ្ទះ និងស្របតាមស្តង់ដាជាតិ ដែលជាគ្រឹះដ៏សំខាន់សម្រាប់អភិវឌ្ឍខួរក្បាលរបស់ពួកគេ។
- លើកកម្ពស់ជីវភាពនិងបង្កើនកម្លាំងចិត្តយ៉ាងខ្លាំងដល់គ្រួមគ្គេយ្យសហគមន៍ឱ្យខិតខំប្រឹងប្រែងបន្ត។
- ប្រជាពលរដ្ឋងាយរងគ្រោះទទួលបានភាពកក់ក្តៅ និងមានអាហារហូបចុះគ្រប់គ្រាន់នៅគ្រាអាសន្ន
- ពង្រឹងជំនឿចិត្ត និងកិច្ចសហការយ៉ាងស្អិតល្មួតរវាងប្រជាពលរដ្ឋនិងរដ្ឋបាលឃុំមោង
- ប្រជាពលរដ្ឋក្នុងឃុំមោងទទួលបានសុវត្ថិភាពខ្ពស់ យល់ដឹងពីផលប៉ះពាល់នៃអំពើហិង្សា និងគ្មានអំពើហិង្សាក្នុងគ្រួសារ។
- ភូមិឃុំមានផាសុកភាព ខ្យល់អាកាសបរិសុទ្ធ ផ្ទះសម្បែងប្រជាពលរដ្ឋមានសោភណ-ភាព គួរឱ្យចង់រស់នៅ កាត់បន្ថយការបំពុលដី ទឹកនិងខ្យល់ដែលបង្កឡើងពីការដុតសំរាមឬបោះចោលសំរាមពាសវាលពាសកាល។



## VI.បទពិសោធន៍ល្អៗ បញ្ហាប្រឈម និងសំណូមពរ

### ❖ បទពិសោធន៍ល្អៗ

- ចំពោះឃុំមោងបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ខ្ពស់និងមានកិច្ចសហការល្អជាមួយគ្រូមត្តេយ្យសហគមន៍ដែលធ្វើឱ្យសាលាមត្តេយ្យសិក្សាសហគមន៍ចំនួន៣សាលាបានទទួលស្គាល់ជាសាលាស្តង់ដាអប្បបរមាពីក្រសួងអប់រំ យុវជន និងកីឡា។
- មានការគាំទ្រមត្តេយ្យសិក្សាសហគមន៍ គាំទ្រចុងភៅចម្អិនអាហារ និងគាំទ្រក្រុមឪពុកម្តាយ
- បានរៀបចំប្រជុំ គ.ក.ន.ក. រៀងរាល់ខែ
- រៀបចំឯកសារធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- គូសផែនទីសេវាសង្គម និងកំណត់គោលដៅ

### ❖ បញ្ហាប្រឈម

- អាណាព្យាបាលមួយចំនួននាំកូនដែលគ្រប់អាយុចូលរៀនថ្នាក់មត្តេយ្យ ចំណាកស្រុកជាមួយគ្រួសារ
- ថវិកាគាំទ្រសេវាសង្គម និងជំនួយឧបត្ថម្ភជួយជនងាយរងគ្រោះនៅមានកំណត់ មិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ពលរដ្ឋបានទាំងអស់១០០%នោះទេ
- ប្រជាពលរដ្ឋមួយចំនួនតូចនៅតែមានទម្លាប់ចាស់ មិនទាន់ចូលរួមពេញលេញក្នុងការគ្រប់គ្រង និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដែលបង្កការលំបាកដល់ការងារអនាម័យបរិស្ថានក្នុងឃុំ។
- គ្រោះធម្មជាតិតែងតែកើតឡើងនិងពិបាកប៉ាន់ស្មាន ដែលធ្វើឱ្យការត្រៀមបម្រុងកញ្ចប់ថវិកាសង្គ្រោះបន្ទាន់ជួបនៅការលំបាក។

## VI.បទពិសោធន៍ល្អៗ បញ្ហាប្រឈម និងសំណូមពរ

❖សំណូមពរ ៖

- ស្នើសុំបញ្ចូលគ្រូពីរសាលាដែលមិនទាន់ស្តង់ដាទៅជាសាលាស្តង់ដាអប្បបរមាសិក្សាសហគមន៍
- ស្នើសុំបញ្ចូលគ្រូស្តង់ដាបីសាលាទៅជាគ្រូក្របខណ្ឌ
- ថវិកាសេវាសង្គមនៅមានកម្រិត សូមបង្កើនថវិកាសេវាសង្គមបន្ថែម។

# សូមអរគុណ !